# តើលោកអ្នកអាចមានរោគរបេងឬ? សញ្ញាខ្លះដែលអាចឲ្យលោកអ្នកដឹងបានថាលោកអ្នកត្រូវការទៅធ្វើតែស៍មើលក្រែងមានរោគបេង

**Are You at Risk for Tuberculosis? Sign that you may need a TB test**

រោគរបេងជារោគមួយដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈខ្យល់អាកាស។ រោគនេះច្រើនធ្វើទុក្ខដល់ប្រពន្ធ័សួត, ប៉ុន្តែវាក៏អាចធ្វើទុក្ខដល់ប្រដាប់ប្រដារផ្សេងទៀត ក្នុងរាងកាយរបស់មនុស្សយើងបានដែរ។

យោលទៅតាមសមាគមន៍អាមេរីកាំងផ្នែកខាងរោគសួត ហៅថា American Lung Association បានឲ្យដឹងថា មនុស្សមួយចំនួនអាចឆ្លងរោគរបេងច្រើងជាងមនុស្សចំនួនទៀត។ អ្នកមានជម្ងឺទឹកនោមផ្អែម, មានមេរោគ HIV ដែលជាមេរោគធ្វើឲ្យកើតជម្ងឺអេដស៍, អ្នកប្រើម្ទុលចាក់ថ្នាំគ្រឿងញៀន, និងអ្នកមានជម្ងឺខ្វះជីវជាតិអាហារ ច្រើនអាចឆ្លងមេរោគរបេង យ៉ាងឆាប់រហ័សជាងមនុស្សដែលពុំមានរោគទាំងនេះ។

ម្យ៉ាងទៀត សមាគមន៍នេះបានបញ្ជាក់ទៀតថា អ្នកដែលធ្វើការនៅក្នុងកន្លែងធ្វើការខ្លះក៏អាចឆ្លងរោគរបេងច្រើនជាងអ្នកធ្វើការនៅកន្លែងខ្លះទៀតបានដែរ។ អ្នកធ្វើការនៅកន្លែងរក្សាចាស់ទុំ Nursing Home, មន្ទីរឃុំឃាំង, មន្ទីរពេទ្យ, និងមណ្ឌលសុខភាពឯទៀតគួរចាក់ថ្នាំធ្វើតែស៍មើល ប្រសិនបើសង្ស័យថាក្រែងខ្លួនមានឆ្លងមេរោគរបេងពីនរណាម្នាក់ ឬក៏មានសញ្ញារោគអ្វីមួយដែលគួរឲ្យសង្ស័យ។

សញ្ញារោគរបស់រោគរបេងមានដូចជា៖ ក្អកខ្លាំងនិងអស់កម្លាំងល្ហិតល្ហៃ, ពុំសូវឃ្លានអាហារ, ស្រកទម្ងន់, បែកញើសនៅពេលយប់, , និងក្អកមានធ្លាក់ឈាម។ ប្រសិនបើលោកអ្នកមានអាការៈរោគទាំងនេះ គួរអញ្ជើញទៅឲ្យគ្រូពេទ្យពិនិត្យជាបន្ទាន់។

ចំពោះពត៌មានបន្ថែមអំពីរោគរបេង សូមមេត្តាអានវិបសៃរបស់ក្រសួងសាធារណៈសុខាភិបាលនៃតរដ្ឋម៉ាសាឈូសេត្ស ដែលមានអស័យដ្ឋាន www.mass.gov/dph ឬ មជ្ឈមណ្ឌលការពារនិងបង្ក្រាបជម្ងឺ Center for Disease Control and Prevention, www.cdc.gov។ ឬពិភាក្សាជាមួយគ្រូពេទ្យប្រចាំកាយរបស់លោកអ្នកផ្ទាល់។

អត្ថបទនេះ ដកស្រង់និងបកប្រែចេញពី Healthfinder ដែលជាកម្មវិធីនៃក្រសួងសុខភាពនិងមនុស្សធម៌នៃសហរដ្ឋ អាមេរិក (Department of Health and Human Services) ដោយ មណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាព សហគមន៍ក្រុងឡូវែល។
http://www.healthfinder.gov/news/newstory.asp?Docid=532781